អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Sep-2012, 16:00
CMS/CFO: Uch Arun

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/ អ.ជ.ស.ដ/អ.ជ.ត.ក(១៧)
Case File/Dossier Nº. 002/19-09-2007-ECCC-TC/SC(17)

**នៅចំពោះមុខ៖** ចៅក្រម គង់ ស្រីម ជាប្រធាន
ចៅក្រម Florence Ndepele Mwachande Mumba
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទ៖** ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់សារណាបន្ថែមលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចដោះលែង អៀង ធីរិទ្ធ

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
អៀង ធីរិទ្ធ

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
ផាត់ ពៅស៊ាង
Diana ELLIS, QC

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖

**ទទួលបាន** បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីការវាយតម្លៃឡើងវិញលើកាយសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ បន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ("បណ្តឹងសាទុក្ខភ្លាមៗ")[1]

**កត់សម្គាល់នូវ** សំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលដាក់សារណាបន្ថែមដើម្បី គាំទ្របណ្តឹងសាទុក្ខភ្លាមៗ "រយៈពេលប្រាំពីរ(០៧)ថ្ងៃ" ចាប់ពីពេលដាក់សារណាបណ្តឹងសាទុក្ខ ដោយមូលហេតុថា " កាលបរិច្ឆេទជាធរមានសម្រាប់បណ្តឹងសាទុក្ខ បានកម្រិតយ៉ាងច្រើននូវលទ្ធភាពរបស់សហព្រះរាជអាជ្ញា ក្នុងការផ្តល់ឱ្យអង្គជំនុំជម្រះនូវសារណាដែលមានលក្ខណៈពេលលេញដោយលើកឡើងនូវទឡ្ហីករណ៍ផ្លូវច្បាប់ដោយលម្អិត និងសេចក្តីយោងទៅលើឯកសារគាំទ្រដែលពាក់ព័ន្ធ" ("សំណើសុំ")[2]

**ដោយពិចារណាឃើញថា** នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ដែលចេញនៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឱ្យដោះលែងជនជាប់ចោទ ដែលត្រូវបានរកឃើញថា ពុំមានសម្បទាដើម្បីចូលរួមសវនាការ ហើយបដិសេធសំណើសុំរបស់សហព្រះរាជ

---

[1] បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការបន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E138/1/10/1/1។

[2] សំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលដាក់សារណាបន្ថែម ដើម្បីគាំទ្របណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យដោះលែងជនជាប់ចោទដោយឥតលក្ខខណ្ឌ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E138/1/10/1/3 ។

អាជ្ញា ដែលស្នើឡើងថា ជនជាប់ចោទត្រូវស្ថិតក្រោមការត្រួពិនិត្យតាមផ្លូវតុលាការ” (“សេចក្តីសម្រេចដែលរងការជំទាស់”)[3]

**ដោយពិចារណាឃើញថា** សហព្រះរាជអាជ្ញា មិនបានប្តឹងសាទុក្ខប្រឆាំងទៅនឹងសេចក្តីសន្និដ្ឋាននៃសេចក្តីសម្រេចដែលរងការជំទាស់ដែលថា ជនជាប់ចោទត្រូវបានដោះលែងឱ្យមានសេរីភាពពីមន្ទីរឃុំឃាំង អ.វ.ត.ក ប៉ុន្តែ គ្រាន់តែប្តឹងលើសេចក្តីសម្រេចនេះ ត្រង់ចំណុចដែលសេចក្តីសម្រេចនេះ បានបដិសេធសំណើសុំរបស់ខ្លួនដែលថា ជនជាប់ចោទត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[4]

**ដោយពិចារណាឃើញថា** សំណើរបស់សហព្រះរាជអាជ្ញា សុំផ្អាកសេចក្តីសម្រេចដែលរងការជំទាស់ ត្រូវបានទទួលយកផ្នែកខ្លះតែប៉ុណ្ណោះ ដូច្នេះ នាពេលបច្ចុប្បន្ននេះ ជនជាប់ចោទត្រូវបានដោះលែងចេញពីមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ដោយស្ថិតក្រោមលក្ខខណ្ឌដូចតទៅ: i) ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែន និងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ, ii) ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាស័យដ្ឋាន ដែលខ្លួនត្រូវស្នាក់នៅ ហើយមិន ត្រូវផ្លាស់ប្តូរទីលំនៅដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ។ iii) ជនជាប់ចោទត្រូវ គោរពតាមដីកាកោះដែលចេញដោយតុលាការ[5]

---

[3] សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារលេខ E138/1/10 ។

[4] បណ្តឹងសាទុក្ខភ្លាមៗ។

[5] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាក់សេចក្តីសម្រេចដោះលែង ជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារលេខ E138/1/10/1/2/1។

**ដោយពិចារណាឃើញថា** បណ្ដឹងសាទុក្ខភ្លាមៗ ពុំស្ថិតក្រោមវិធាន ៨២(៦) នៃវិធានផ្ទៃក្នុង ប៉ុន្តែ បណ្ដឹងសាទុក្ខនេះ ស្ថិតក្រោមរបបនីតិវិធីដែលមានចែងក្នុងវិធាន ១០៧(២) នៃវិធានផ្ទៃក្នុង និង ១០៨(៤)(ស្ទួន)(ក) ដោយកំណត់រយៈពេល ១៥ ថ្ងៃ ក្នុងការដាក់បណ្ដឹងសាទុក្ខ និងបី(០៣) ខែ ដើម្បីសម្រេចលើបណ្ដឹងសាទុក្ខនេះ

**ដោយអនុលោមតាម** វិធាន ១០៧(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៨) និងមាត្រា ៨(៣) នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (វិសោធនកម្មលើកទី ៨)

**សម្រេច:**

**ទទួលយក** សំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំការអនុញ្ញាតពន្យារពេលដើម្បីដាក់សារណាបន្ថែមជាលាយលក្ខណ៍អក្សរឱ្យបានមុនថ្ងៃ សុក្រ ទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២។

**រំលឹកដល់** ជនជាប់ចោទថា សារណាតបណាមួយទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗនេះ ត្រូវដាក់ត្រឹមថ្ងៃ ចន្ទ័ ទី ០៨ ខែ តុលា ឆ្នាំ ២០១២។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**